**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧១៤៦ សហវ.អគត

ថ្ងៃ ចន្ទ ៧ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២១

**ជម្រាបជូន**

**លោកបណ្ឌិត សរ ចិន្ត្រា អគ្គលេខាធិការរង និងជានាយកគម្រោងពិពិធកម្មកសិកម្មកម្ពុជា**

**នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ស្នើសម្របសម្រួលផ្តល់ដំណឹងជូន "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" និង "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ពីលទ្ធផលនៃការវាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ច ក្រោមក្របខ័ណ្ឌគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP)។

**ភ្ជាប់ជូន៖** -របាយការណ៍ពិនិត្យនិងអនុម័តរបស់ AEC ចំនួន ០១ ច្បាប់,

-របាយការណ៍វាយតម្លៃរបស់ EC លើសំណើពិពិធកម្ម និងធុរកិច្ច ចំនួន ០១ ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **លោកបណ្ឌិត** ឱ្យបានជ្រាបថា៖ កាលពីថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២១ គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (AEC) បានបើកកិច្ចប្រជុំពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" និង "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ដែលបានរៀបចំដោយគណៈកម្មការវាយតម្លៃ (EC)។ យោងតាមលទ្ធផលនៃការវាយតម្លៃបានបង្ហាញថា សំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" ទទួលបានពិន្ទុសរុបចំនួន **៧០.៨០** ពិន្ទុ, ចំណែកឯ "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ទទួលបានពិន្ទុសរុបចំនួន **៧៦.៤០** ពិន្ទុ ដោយបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ និងអាចបន្តទៅដំណាក់កាលបន្ទាប់ក្នុងការរៀបចំសរសេរផែនការពិពិធកម្មនិងធុរកិច្ច។ គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត ក៏បានពិនិត្យ និងឯកភាពលើលទ្ធផលនៃការវាយតម្លៃរបស់គណៈកម្មការ EC ផងដែរ។

ក្នុងន័យនេះ ដើម្បីបំពេញតាមនីតិវិធីនៃការអនុវត្តគម្រោង, ខ្ញុំសូមស្នើ អង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Project Coordination Office-PCO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្របសម្រួលផ្តល់ដំណឹងជូន "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" និង "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" អំពីលទ្ធផលដូចមានរបាយការណ៍ភ្ជាប់ជូន និង ចុះផ្សាយក្នុងគេហទំព័ររបស់គម្រោងសម្រាប់ជាព័ត៌មានបន្ថែម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកបណ្ឌិត** ពិនិត្យ និងចាត់ចែង តាមការគួរ។

សូម **លោកបណ្ឌិត** ទទួលនូវការរាប់អានពីខ្ញុំ។

**អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការប្រឹក្សាយោបល់និងអនុម័ត នៃគម្រោង CASDP**

**កេត តិយ៉ារិទ្ធ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦

Phone: (+855)23 890 666

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា**

# របាយការណ៍កិច្ចប្រជុំ
## គណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

### ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២១, គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (Advisory and Endorsement Committee-AEC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើពិពិធកម្មកសិកម្ម (DPr) របស់ **"សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី"** និង **"សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង"** ដែលបានរៀបចំឡើងដោយគណៈកម្មការវាយតម្លៃ (Evaluation Committee-EC) កាលពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២១ កន្លងទៅ។ កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងសម្រេចជាផ្លូវការ ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍កសិកម្មបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ចលម្អិត មុននឹងផ្តល់ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគដល់សហគមន៍។

### ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំគណៈកម្មការ AEC ត្រូវបានរៀបចំឡើងដោយអង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF-PIU/CASDP) ក្រោមអធិបតីភាព **ឯកឧត្តម ទេព តិយ៉ាវិន្ទ្រ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការ AEC ព្រមទាំងមានការចូលរួមពីសំណាក់សមាជិកនៃគណៈកម្មការចំនួន ០៧ រូប រួមមាន ÷ ឯកឧត្តម **ជ្រាយ ប៉ុម**, លោកបណ្ឌិត **សរ ចិត្រា**, លោក **សុខ ខន**, លោក **អ៊ឹម សួស្តី**, លោកឧកញ៉ា **ហង់ សុគន្ធ**, ឯកឧត្តម **ម៉េង និមល** និងលោក **គា បូរាណ**។

### ៣. លទ្ធផលនៃកិច្ចប្រជុំ និងផែនការសកម្មភាព

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ទេព តិយ៉ាវិន្ទ្រ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការ AEC បានថ្លែងនូវមតិស្វាគមន៍ដល់សមាជិកនៃអង្គប្រជុំទាំងមូល និងបានបញ្ជាក់ពីគោលបំណងសំខាន់ៗនៃ

កិច្ចប្រជុំនេះ ព្រមទាំងបានផ្តល់សារគន្លឹះមួយចំនួនពាក់ព័ន្ធនឹងការពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើ DPr របស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" និង "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ដែលបានរៀបចំដោយគណៈកម្មការ EC កាលពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២១។

ជាកិច្ចបន្ទាប់ **លោក បាន កុសល** អនុប្រធាននាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ និងជាលេខាធិការនៃគណៈកម្មការ EC បានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំដោយសង្ខេបអំពីសាវតា និងលទ្ធផលនៃការវាយតម្លៃសំណើ DPr ដូចខាងក្រោម៖

១. **សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី** មានទីតាំងស្ថិតនៅភូមិក្រាំងសេរី ឃុំគីរីវ័ន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ តាមរយៈលិខិតចុះបញ្ជីលេខ ០៤៣ កស្ក/ស.ក.ក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៧។

   - សំណើពិពិធកម្មកសិកម្មរបស់សហគមន៍ គឺផ្តោតលើ "**ពង្រីកទំហំផលិតកម្មមាន់សាច់ពូជក្នុងស្រុក**" ដែលមានសមាជិកក្នុងក្រុមផលិតសរុប ៤០ គ្រួសារ ក្នុងនោះមានស្ត្រីចំនួន ២៣ នាក់ (អ្នកទទួលផលសរុបចំនួន ១៧៩ នាក់ មានស្ត្រីចំនួន ១១៥)។
   - ផែនការថវិកា ដែលគ្រោងប្រើប្រាស់សម្រាប់ផលិតកម្មមាន់សាច់ពូជក្នុងស្រុកសរុបចំនួន **១៧៣,២០៩.៥០** ដុល្លារអាមេរិក ក្នុងនោះសហគមន៍គ្រោងស្នើសុំកម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប **៥៦,០៣១.៤០** ដុល្លារអាមេរិក, ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប **៣៣,៤៣៥.៦០** ដុល្លារអាមេរិក, ថវិកាបដិភាគពីសហគមន៍កសិកម្ម និងសមាជិកក្រុមផលិតចូលរួមសរុប **៨៣,៦៤២.៥០** ដុល្លារអាមេរិក។
   - លទ្ធផលនៃការវាយតម្លៃលើ សំណើពិពិធកម្មកសិកម្មរបស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" ទទួលបានពិន្ទុចំនួន **៧០.៨០ ពិន្ទុ** លើពិន្ទុសរុប ១០០ពិន្ទុ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ច។

២. **សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង** មានទីតាំងស្ថិតនៅភូមិ ត្រពាំងត្នោត ឃុំស្វាយសែន ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម តាមរយៈលិខិតចុះបញ្ជីលេខ ៦៦៣ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១៦ និងវិញ្ញាបនបត្រលេខ ៦៦០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១៦។

- សំណើពិពិធកម្មកសិកម្មរបស់សហគមន៍ គឺផ្តោតលើការ **"ពង្រីកផលិតកម្ម និងទីផ្សារគោសាច់ពូជក្នុងស្រុក និងបន្លែសុវត្ថិភាព"** ដែលមានសមាជិកក្នុងក្រុមផលិតសរុប ៤៦ នាក់ (ក្រុមផលិតបន្លែសុវត្ថិភាព ចំនួន ២០ នាក់ និងក្រុមចិញ្ចឹមគោសាច់ពូជក្នុងស្រុកចំនួន ២៦ នាក់) ក្នុងនោះមានស្ត្រីចំនួន ១៩ នាក់។
- ផែនការថវិកា ដែលគ្រោងប្រើប្រាស់សម្រាប់ពង្រីកខ្សែច្រវាក់ផលិតកម្មគោសាច់ក្នុងស្រុកសរុបចំនួន **១៤៩,៧៦៤** ដុល្លារអាមេរិក ក្នុងនោះសហគមន៍គ្រោងស្នើសុំហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុន-វិនិយោគពីគម្រោង CASDP សរុប **៤០,៥៤០.២៨** ដុល្លារអាមេរិក និងថវិកាបដិភាគពីសមាជិកក្រុមផលិតចូលរួមសរុប **១០៩,២២៣.៧២** ដុល្លារអាមេរិក។
- ផែនការថវិកា ដែលគ្រោងប្រើប្រាស់សម្រាប់ពង្រឹងប្រព័ន្ធខ្សែច្រវាក់ផលិតកម្មបន្លែសុវត្ថិភាពសរុបចំនួន **១៣៤,៦០៥.៥០** ដុល្លារអាមេរិក ក្នុងនោះសហគមន៍គ្រោងស្នើសុំហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប **៤៦,២៩៣.៥០** ដុល្លារអាមេរិក និងថវិកាបដិភាគពីសមាជិកក្រុមផលិតចូលរួមសរុប **៨៨,៣១២** ដុល្លារអាមេរិក។
- លទ្ធផលនៃការវាយតម្លៃលើសំណើពិពិធកម្មកសិកម្មរបស់សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើងទទួលបានពិន្ទុចំនួន **៧៦.៤០ ពិន្ទុ** លើពិន្ទុសរុប ១០០ពិន្ទុ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ច។

ក្រោយពីសេចក្តីរាយការណ៍បានបញ្ចប់ អង្គប្រជុំបានធ្វើការពិនិត្យ និងពិភាក្សាលើរបាយការណ៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនីមួយៗ ដោយទទួលបានលទ្ធផលចំនួនសម្លេង ៨ លើ ៨ ក្នុងការសម្រេចគាំទ្រ និងឯកភាពលើរបាយការណ៍វាយតម្លៃរបស់គណៈកម្មការ EC។ ទន្ទឹមនេះ អង្គប្រជុំក៏បានយល់ព្រមផ្តល់លទ្ធផលនៃកិច្ចប្រជុំនេះ ជូនទៅអង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Project Coordination Office-PCO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្របសម្រួលផ្តល់ដំណឹងជូន **"សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី"** និង **"សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង"** អំពីលទ្ធផលនៃការវាយតម្លៃសំណើ DPr របស់សហគមន៍នីមួយៗ និងចុះផ្សាយលទ្ធផលនេះក្នុងគេហទំព័ររបស់គម្រោង។

ជាកិច្ចបញ្ចប់ **ឯកឧត្តម ទេព តិរយ្យោរិន្ទ្រ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈ-កម្មការ AEC បានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលបានចូលរួម និងស្នើសុំសមាជិកទាំងអស់បន្តចូលរួមកិច្ចប្រជុំបន្ទាប់ដែលគ្រោងរៀបចំឡើង **នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២១ វេលាម៉ោង ១៥ :០០ នាទី** ដើម្បីបន្តពិនិត្យ និង

អនុម័តលើសំណើពិពិធកម្មនិងសំណើធុរកិច្ចរបស់ “**សហគមន៍កសិកម្មអញ្ញាញ្ញូងសម័យថ្មី**” និង “**សហគមន៍កសិកម្មកសិករសាមគ្គីអមលាំង**”។ **ឯកឧត្តមអនុរដ្ឋលេខាធិការ** ប្រធានអង្គប្រជុំ បានប្រកាសបិទអង្គប្រជុំនៅថ្ងៃដដែលវេលាម៉ោង ១៧:០០ នាទី។

ថ្ងៃអង្គារ ១ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១
**រៀបចំដោយ**
**លេខាធិការ**

**ឱ សេរីវីរៈ**

ថ្ងៃ សុក្រ ៤រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែសីហាឆ្នាំ២០២១
**យោបល់**

**អនុរដ្ឋលេខាធិការ និង ជាប្រធានគណៈកម្មការ**
**ប្រឹក្សាយោបល់ និងអនុម័ត AEC**

**ទេព ភិយ្យោរិន្ទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា

# របាយការណ៍កិច្ចប្រជុំ
# គណៈកម្មការវាយតម្លៃ នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

## ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី **១៧** ខែសីហា ឆ្នាំ ២០២១, គណៈកម្មការវាយតម្លៃ (Evaluation Committee-EC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្មរបស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" និង "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" មុននឹងបញ្ជូនបន្តទៅកាន់គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (Advisory and Endorsement Committee-AEC) ដើម្បីពិនិត្យ និងអនុម័តជាផ្លូវការ មុននឹងអនុញ្ញាតឱ្យសហគមន៍កសិកម្មរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្តទៀត។

## ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំត្រូវបានដឹកនាំដោយ **លោក ឡៅ ប៉ូលីវេត** អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ និងជាប្រធានគណៈកម្មការវាយតម្លៃ (EC) ដោយមានការចូលរួមពីសមាជិក នៃគណៈកម្មការចំនួន ០៦ រួមមាន÷ (១). លោក **ហុក គឹមឆួន**, (២). លោក **ឆេង វិបុលរិទ្ធ**, (៣). លោក **ទិត្យ សុជា**, (៤). លោកស្រី **ឡាំង សុខគីម** (តំណាងឱ្យលោក សុខ បូរ៉ែន), (៥). លោកស្រី **ជា សុខអ៊ីម** និង (៦). លោកស្រី **ហ៊ីង លីហ្វង** (តំណាងឱ្យលោក សុខ រឿន)។ លោក **ដុក លួន** សមាជិកគណៈកម្មការ EC បានអវត្តមានក្នុងកិច្ចប្រជុំនេះ។

## ៣. សេចក្តីសង្ខេបពីសំណើពិពិធកម្ម និងធុរកិច្ច

**១. *សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី*** មានទីតាំងស្ថិតនៅភូមិក្រាំងសេរី ឃុំគីរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សហគមន៍កសិកម្មរួមជាមួយក្រុមផលិតចំនួន ១ ក្រុម បានចូលរួមដាក់សំណើ (ផលិតមាន់សាច់ពូជក្នុងស្រុក) ដែលមានសមាជិកក្នុងក្រុមផលិតសរុប ៤០ គ្រួសារ ក្នុងនោះមានស្ត្រី ២៣ នាក់ (អ្នកទទួលផលសរុបចំនួន ១៧៩ នាក់ មានស្ត្រីចំនួន ១១៥ នាក់)។ តាមច្បាប់ស្តីពីសហគមន៍កសិកម្ម ដែលប្រកាសឱ្យប្រើប្រាស់ជាផ្លូវការតាមព្រះរាជក្រមលេខនស/រកម/០៦១៣/០៨ ចុះ

ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៣ **សហគមន៍កសិកម្មសាមគ្គីក្រាំងសើរ** បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ តាមរយៈលិខិតចុះបញ្ជីលេខ ០៤៣ កស្ព/ស.ក.ក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៧។ សហគមន៍កសិកម្មមានមុខរបរចម្បងៗដែលកំពុងដំណើរការសព្វថ្ងៃរួមមាន÷ បន្លែសុវត្ថិភាព, ឥណទានកសិកម្ម, ប្រព័ន្ធចែកចាយទឹក និងមុខរបរពីរទៀតគឺ ការចិញ្ចឹមមាន់សាច់ និងភ្ញាស់កូនមាន់ (ជាអាជីវកម្មដែលមានសក្តានុពលជាងគេក្នុងសហគមន៍)។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្ម (CASDP), សហគមន៍កសិកម្មសាមគ្គីក្រាំងសើរ បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ច ដោយផ្តោតលើការ"**ពង្រីកទំហំផលិតកម្មមាន់សាច់ពូជក្នុងស្រុក**" ដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មរបស់សហគមន៍កសិកម្មសាមគ្គីក្រាំងសើរ គឺពង្រីកទំហំផលិតកម្មមាន់សាច់សុវត្ថិភាពពូជក្នុងស្រុកជាមធ្យម ៧២ តោន/ឆ្នាំ និងផ្គត់ផ្គង់កូនមាន់ ៥៥,២០០ ក្បាល/ខែ ដើម្បីបង្កើនប្រាក់ចំណូលជូលរបស់សមាជិកក្រុមផលិត គិតជាមធ្យមចំនួន ៨៦៦,៩៧០ ដុល្លារអាមេរិក និងចំណូលដល់សហគមន៍កសិកម្មចំនួន ២៨៣,០៨០ ដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ តាមរយៈការពង្រីកទំហំចិញ្ចឹមមាន់សាច់, ការអនុវត្តតាមបច្ចេកទេសថ្មី, ការប្រមូលផ្តុំទិញ-លក់, ការកែលម្អខ្សែច្រវាក់ផលិតកម្មប្រកបដោយគុណភាពល្អ និងតាមស្តង់ដារសុវត្ថិភាព ដែលគ្រោងនឹងចំណាយសរុបចំនួន **១៧៣,២០៩.៥០** ដុល្លារអាមេរិក ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម ÷

**ក. អាជីវកម្មរបស់ក្រុមផលិត**

- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប **៤៣,០៦៧.៤០** ដុល្លារអាមេរិក
- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប **២៨,៧១១.៦០** ដុល្លារអាមេរិក
- ថវិកាបដិភាគពីសមាជិកក្រុមផលិតចូលរួមសរុប **៨៣,៦៤២.៥០** ដុល្លារអាមេរិក

ដូច្នេះអាជីវកម្មរបស់ក្រុមផលិត សរុបជាទឹកប្រាក់ស្មើនឹង **១៥៥,៤២១.៥០** ដុល្លារអាមេរិក។

**ខ. អាជីវកម្មរបស់សហគមន៍**

- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប **១២,៩៦៤** ដុល្លារអាមេរិក
- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប **៤,៧២៤** ដុល្លារអាមេរិក

ដូច្នេះអាជីវកម្មរបស់សហគមន៍ សរុបជាទឹកប្រាក់ស្មើនឹង **១៧,៧៨៨** ដុល្លារអាមេរិក។

**២. សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង** បានបង្កើតឡើង នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៧ មានទីតាំងស្ថិតនៅភូមិត្រពាំងឆ្នោត ឃុំសូរ្យសែន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ សហគមន៍កសិកម្មរួមជាមួយក្រុមផលិតចំនួន ២ ក្រុម បានចូលរួមដាក់សំណើ ដែលមានសមាជិកក្នុងក្រុមផលិតសរុប ៤៦ នាក់ (ក្រុមផលិតបន្លែសុវត្ថិភាពចំនួន ២០ នាក់ និងក្រុមចិញ្ចឹមគោសាច់ពូជក្នុងស្រុកចំនួន ២៦ នាក់) ក្នុងនោះមានស្ត្រីចំនួន ១៩ នាក់។ សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើងហៅកាត់ថា ស.ក.អ.ស.យ. និងជាភាសាអង់គ្លេស Akphivat Srok Yoeung Agricultural Cooperative (ASYAC) បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម តាមរយៈលិខិតចុះបញ្ជីលេខ ៦៦៣ ចុះថ្ងៃទី ៣០ ខែធ្នូ

ឆ្នាំ ២០១៦ និងវិញ្ញាបនបត្រលេខ ៦៦០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១៦។ សហគមន៍កសិកម្មមានមុខរបរចម្រុះៗដែលកំពុងដំណើរការសព្វថ្ងៃរួមមាន÷ ឥណទានសាច់ប្រាក់ សន្សំប្រាក់ ទិញលក់ស្រូវ កែច្នៃស្រូវអង្ករ លក់ធាតុចូលកសិកម្ម (ជីកសិកម្ម) ចិញ្ចឹមមាន់ គោ និងដាំបន្លែ។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ច មានតម្រូវការទឹកប្រាក់សរុបចំនួន ២៨៤,៣៦៩.៥០ ដុល្លារអាមេរិក ដោយផ្តោតលើការ**"ពង្រីកផលិតកម្ម និងទីផ្សារគោសាច់ពូជក្នុងស្រុក និងបន្លែសុវត្ថិភាព"** ដើម្បីដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធក្នុងការពិនិត្យពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។ សំណើពិពិធកម្មនិងធុរកិច្ចនេះបានរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ ដូចខាងក្រោម÷

**គោលបំណងទី១** ពង្រឹងប្រព័ន្ធខ្សែច្រវាក់ផលិតកម្មបន្លែសុវត្ថិភាពរបស់ក្រុមផលិតក្នុងរយៈពេល ៣ ឆ្នាំ ឱ្យសម្រេចបានបរិមាណផលចំនួន ១,៩៣៥ តោន ដើម្បីទទួលបានប្រាក់ចំណូលដុល ៧១៨,៨៤០.២៥ ដុល្លារអាមេរិក តាមរយៈការកែលម្អបច្ចេកទេសដាំដុះ, ផែនការផលិតកម្មវិលជុំ និងពង្រីកទីផ្សារ ដែលគ្រោងនឹងចំណាយសរុប ១៣៤,៦០៥.៥០ ដុល្លារអាមេរិក ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤៦,២៩៣.៥០ ដុល្លារអាមេរិក
- ថវិកាបដិភាគពីសមាជិកក្រុមផលិតចូលរួមសរុប ៨៨,៣១២ ដុល្លារអាមេរិក

**គោលបំណងទី២** លើកកម្ពស់ទីផ្សារសាច់គោពូជក្នុងស្រុក តាមរយៈការពង្រីកខ្សែច្រវាក់ផលិតកម្មគោសាច់ពីចំនួន ២៩១ ក្បាល ក្នុង ១ ឆ្នាំ (មុនគម្រោង) ទៅ ៤៨៩ ក្បាល ក្នុង ១ ឆ្នាំ នាឆ្នាំទី ៣ នៃគម្រោង (សរុប ១,២៣៣ ក្បាល ដោយទទួលបានប្រាក់ចំណូលសរុប ១,០០៤,៨១២.៥០ ដុល្លារអាមេរិកក្នុងរយៈពេល ៣ ឆ្នាំ) តាមរយៈការកែលម្អបច្ចេកទេសចិញ្ចឹម និងអនុវត្តផែនការពង្រីកផលិតកម្មសម្រាប់ផ្គត់ផ្គង់តម្រូវការទីផ្សារ ដែលគ្រោងនឹងចំណាយសរុប ១៤៩,៧៦៤ ដុល្លារអាមេរិក ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤០,៥៤០.២៨ ដុល្លារអាមេរិក
- ថវិកាបដិភាគពីសមាជិកក្រុមផលិតចូលរួមសរុប ១០៩,២២៣.៧២ ដុល្លារអាមេរិក

## ៤. នីតិវិធីនៃការវាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្ម

ការដាក់ពិន្ទុលើសំណើពិពិកម្ម (DPr) ត្រូវបានធ្វើឡើងដោយសមាជិកគណៈកម្មការ EC ម្នាក់ៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាគោលចំនួន ៧ រួមមាន÷ ១) ភាពពាក់ព័ន្ធរបស់ DPr ជាមួយក្របខណ្ឌគម្រោង, ២) បទពិសោធន៍របស់តួអង្គពាក់ព័ន្ធក្នុងការប្រកបអាជីវកម្ម, ៣) ការរៀបចំ DPr/BPr, ៤) ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប, ៥) ការវិភាគហិរញ្ញវត្ថុ, ៦) ផលជះផ្នែកបរិស្ថាន និង ៧) ផលជះផ្នែកសង្គមរបស់គម្រោង។ សមាជិកម្នាក់ធ្វើការដាក់ពិន្ទុលើសំណើ ចន្លោះពី ១ ទៅ១០០ ពិន្ទុលើសំណើពិពិធកម្ម ម្តងមួយៗ។ ទន្ទឹមនេះ ពិន្ទុដែលផ្តល់ដោយសមាជិកម្នាក់ៗ នៃគណៈកម្មការវាយតម្លៃ មិនត្រូវបានអនុញ្ញាត

ឱ្យចែករំលែកដល់សមាជិកគណៈកម្មការដ៏ទៃទៀតដឹងនោះឡើយ។ សំណើពិពិធកម្មមួយដែលត្រូវបានវាយតម្លៃដោយសមាជិកគណៈកម្មការ EC ចំនួន ៨ រូប គឺអាចមានពិន្ទុអតិបរមាត្រឹម ៨០០ ពិន្ទុ។

## ៥. លទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុ

តាមរយៈការធ្វើមធ្យមភាគនៃពិន្ទុទាំងអស់របស់សមាជិកគណៈកម្មការ EC លើសំណើពិពិធកម្មរបស់សហគមន៍កសិកម្មទាំងពីរខាងលើនេះ បានបង្ហាញឱ្យឃើញថាពិន្ទុសរុបជាមធ្យមនៃ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" ទទួលបានចំនួន **៧០.៨០** ពិន្ទុ លើពិន្ទុសរុប ១០០ ។ ចំណែកឯ "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ទទួលបានពិន្ទុចំនួន **៧៦.៤០** លើពិន្ទុសរុប ១០០ ។

ការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរបស់សមាជិកគណៈកម្មការ EC ម្នាក់ៗ មានខ្លឹមសារលម្អិតក្នុងតារាងខាងក្រោម÷

# គណៈកម្មការវាយតម្លៃ សំណើពិពិធកម្មកសិកម្ម របស់សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃDPr ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPr គឺរៀបចំសរសេរបានល្អ<br>The rationale and object ves of the proposed DPr are well formulated | 5 | 3 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.8 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPr នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោង CASDP<br>The relevance of the proposed DPr to reach the objective of the CASDP project | 5 | 4 | 3 | 4 | 3 | 4 | 4 | 4 | 3 | 3.6 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់តួអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំគិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី Average year of legal constitution of POs and SMAs | 5 | 3 | 4 | 3 | 4 | 3 | 4 | 4 | 4 | 3.6 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ =២;<br>តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតផលរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 3 | 3 | 3 | 3 | 3 | 4 | 4 | 3.3 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPr នីមួយៗ របស់ DPr មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណង ក្នុងការ ទិញទំនិញពីដៃគូអ្នកបញ្ជា ទិញ Each BPI of the DPr is supported by a letter of intent of purchase by a potential buyer. | 5 | 5 | 3 | 3 | 3 | 5 | 5 | 5 | 5 | 4.3 | BPr ទាំងអស់ = ៥;<br>ខ្លះៗ = ៣;<br>ពុំមានសោះ = ១ |
| **៣. ការរៀបចំDPr/ BPr** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPr របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមគឺត្រឹមត្រូវ និងសមស្រប ដែលនឹងអាចសម្រេច បាននៅតាមគោលដៅ របស់ DPr និង BPr ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង (Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPr and BPI and the development objective of the Project.) | 10 | 8 | 8 | 8 | 8 | 6 | 8 | 8 | 6 | 7.5 | ទាំងស្រុង (Totally) = ១០;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |
| | ៣.២. សំណើ BPr នៅក្នុង DPr គឺមានដាក់បញ្ចូលនូវ ដំណើរការក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្មដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍ BPr in DPr include/s innovative technological and commercial processes at farm, aggregation, processing anc marketing level. | 5 | 4 | 4 | 3 | 3 | 3 | 4 | 4 | 3 | 3.5 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៣. សំណើ BPr នៅក្នុង DPr មានការដាក់បញ្ចូលនូវ ការបន្ថែមតម្លៃលើ ផលិតផល កសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែច្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាកសម្គាល់ ជាដើម BPr in DPr propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 3 | 3 | 4 | 4 | 4 | 3 | 3 | 2 | 3.3 | ទាំងស្រុង (Totally) = ៥; បង្គួរ (substantially)= ៤; ភាគច្រើន (mostly)= ៣; ល្មមគ្រប់គ្រាន់ (just enough)= ២; មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៤. សំណើវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើស យ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPr និងគោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមានលក្ខណៈ សមស្រប Supporting public investments are well chosen to support achieving the objective of the DPr and the development objective of the Project, and are within acceptable budget | 5 | 3 | 3 | 4 | 3 | 2 | 4 | 4 | 3 | 3.3 | ទាំងស្រុង (Totally)= ៥; បង្គួរ (substantially)= ៤; ភាគច្រើន (mostly)= ៣; ល្មមគ្រប់គ្រាន់ (just enough)= ២; មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៥. BPr នៅក្នុង DPr មាន អំណះអំណាងច្បាស់លាស់ ដែលបញ្ជាក់ថា តម្រូវការទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង The BPr under the DPr is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 4 | 4 | 4 | 3 | 4 | 4 | 4 | 3.9 | ទាំងស្រុង (Totally) = ៥; បង្គួរ (substantially)= ៤; ភាគច្រើន (mostly) = ៣; ល្មមគ្រប់គ្រាន់ (just enough)= ២; មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPr នៅក្នុង DPr បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និង ការអនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃ ផលិតផលកសិកម្ម (GMP) BPr under DPr explicitly incorporate good agricultural practices and good manufacturing practices | 5 | 5 | 3 | 3 | 5 | 3 | 3 | 3 | 3 | 3.5 | ទាំងពីរ (Both) = ៥; មួយក្នុងចំណោមទាំងពីរ (One of them) = ៣; មិនមានណាមួយ (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាតតូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ? Are current risks and mitigation measures well formulated? | 5 | 4 | 4 | 3 | 4 | 3 | 4 | 4 | 4 | 3.8 | ទាំងស្រុង (Totally) = ៥; បង្គួរ (substantially) = ៤; ភាគច្រើន (mostly) = ៣; ល្មមគ្រប់គ្រាន់ (just enough) = ២; មិនគ្រប់គ្រាន់ (not enough) = ១ |
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើងដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥; រហូតដល់ ១០% (Up to 10%) = ៣; រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន? What is the impact of the project on the environment? | 5 | 4 | 3 | 4 | 5 | 3 | 4 | 4 | 4 | 3.9 | វិជ្ជមានខ្ពស់ (Very Positive) = ៥; វិជ្ជមាន (Positive) = ៤; វិជ្ជមានដែរ (rather positive) = ៣; ធម្មតា (Neutral) = ២; អវិជ្ជមាន(Negative)=១ |

| ៧. ផលជះផ្នែកសង្គមរបស់គម្រោង | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោងដែរឬទេ? Are adverse social impacts identified? | 5 | 3 | 3 | 3 | 3 | 3 | 3 | 5 | 5 | 3.5 | ទាំងស្រុង (Totally) = ៥; ភាគច្រើន (mcstly)= ៣;<br>មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPr នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និង ការងារតាមរដូវកាល) Does the DPr create new jobs (permanent and seasonal) | 5 | 2 | 3 | 3 | 2 | 2 | 2 | 2 | 2 | 2.3 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (none) = ១ |
| ៧.៣. តើ DPr នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះឯទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ? Does the DPr has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 3 | 3 | 4 | 3 | 3 | 4 | 5 | 3 | 3.5 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPr និងសំណើព្រវាក់តម្លៃ ដែលបានជ្រើសរើស មានវិចិត្តភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយសំណើទាំងនោះ អាចត្រូវបានកំណត់ថាជាសំណើដែលជានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutr'tion-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 3 | 3 | 4 | 4 | 3 | 4 | 3 | 3 | 3.4 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| ៧.៥. តើ BPr និងសំណើខ្សែព្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយសំណើទាំងនោះអាចត្រូវបានកំណត់ថាជាសំណើដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ? Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 2 | 2 | 2 | 2 | 1 | 3 | 3 | 2 | 2.1 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| Total Score | 100 | 71 | 67 | 71 | 72 | 63 | 75 | 78 | 69 | 70.8 | |

# គណៈកម្មការវាយតម្លៃ សំណើពិពិធកម្មកសិកម្ម របស់សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| ១. ភាពពាក់ព័ន្ធនៃDPr ជាមួយក្របខ័ណ្ឌគម្រោង | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPr ពីរៀបចំសរសេរបានល្អ The rationale and objectives of the proposed DPr are well formulated | 5 | 3 | 4 | 5 | 4 | 5 | 4 | 4 | 4 | 4.1 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPr នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោង CASDP The relevance of the proposed DPr to reach the objective of the CASDP project | 5 | 4 | 4 | 5 | 4 | 4 | 4 | 4 | 4 | 4.1 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| ២. បទពិសោធន៍របស់គូអង្គពាក់ព័ន្ធ | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំពិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិពាណិជ្ជខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី Average year of legal constitution of POs and SMAs | 5 | 3 | 4 | 3 | 4 | 4 | 4 | 4 | 4 | 3.8 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ =២,<br>តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតរបស់ខ្លួនរួមគ្នាជាក្រុម Experience of PO to market their products together as a group | 5 | 3 | 4 | 4 | 2 | 3 | 3 | 4 | 4 | 3.4 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPr នីមួយៗ របស់ DPr មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណងក្នុងការ ទិញ ទំនិញពីដៃគូអ្នកបញ្ជា ទិញ Each BPI of the DPr is supported by a letter of intent of purchase by a potential buyer. | 5 | 5 | 3 | 5 | 3 | 5 | 5 | 5 | 5 | 4.5 | BPr ទាំងអស់ = ៥;<br>ខ្លះៗ = ៣;<br>ពុំមានសោះ = ១ |
| ៣. ការរៀបចំDPr/ BPr | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPr របស់ក្រុមផលិត និងកសិពាណិជ្ជខ្នាតតូច និងមធ្យមពិត្រឹមត្រូវ និងសម ស្រប ដែលនឹងអាចសម្រេច បាន នៅតាមគោលដៅ របស់ DPr និង BPr ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង (Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPr and BPI and the development objective of the Project.) | 10 | 8 | 8 | 8 | 8 | 8 | 8 | 8 | 8 | 8.0 | ទាំងស្រុង (Totally) = ១០;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២. សំណើ BPr នៅក្នុង DPr ពីមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈ<br>នវានុវត្តន៍ BPr in DPr include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 4 | 4 | 4 | 4 | 4 | 4 | 4 | 3 | 3.9 | ទាំងស្រុង (Totally) = ៥<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៣. សំណើ BPr នៅក្នុង DPr មានការដាក់បញ្ចូលនូវ ការបន្ថែមតម្លៃដល់ផលិតផលកសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែច្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាក សម្គាល់ ជាដើម BPr in DPr propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 4 | 3 | 4 | 4 | 3 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)=៤;<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៤. សំណើវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPr និងគោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមានលក្ខណៈ សមស្រប Supporting public investments are well chosen to support achieving the objective of the DPr and the development objective of the Project, and are within acceptable budget | 5 | 4 | 3 | 5 | 3 | 5 | 4 | 4 | 4 | 4.0 | ទាំងស្រុង (Totally)=៥;<br>បង្គួរ (substantially)=៤;<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៥. BPr នៅក្នុង DPr មាន អំណះអំណាងច្បាស់លាស់ ដែលបញ្ជាក់ថា តម្រូវការទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង The BPr under the DPr is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 4 | 5 | 4 | 4 | 5 | 5 | 4 | 4.4 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough = ១ |
| ៣.៦. BPr នៅក្នុង DPr បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃផលិតផលកសិកម្ម (GMP) BPr under DPr explicitly incorporate good agricultural practices and good manufacturing practices | 5 | 5 | 4 | 3 | 3 | 5 | 3 | 5 | 3 | 3.9 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានណាមួយ (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាតតូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ? Are current risks and mitigation measures well formulated? | 5 | 4 | 4 | 3 | 4 | 4 | 4 | 4 | 4 | 3.9 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២; |
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផល<br>ចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើងដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន? What is the impact of the project on the environment? | 5 | 4 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.9 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>ធម្មតា (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោងដែរឬទេ? Are adverse social impacts identified? | 5 | 3 | 3 | 3 | 5 | 3 | 3 | 5 | 3 | 3.5 | ទាំងស្រុង (Totally) = ៥; ភាគច្រើន (mostly)= ៣; មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPr នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល) Does the DPr create new jobs (permanent and seasonal) | 5 | 2 | 3 | 4 | 2 | 2 | 2 | 2 | 4 | 2.6 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (rone) = ១ |
| ៧.៣. តើ DPr នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះផ្សេងទៀតនឹងទទួលបាន ផលប្រយោជន៍ពីគម្រោង ដែរឬទេ? Does the DPr has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 3 | 3 | 5 | 3 | 4 | 5 | 5 | 4 | 4.0 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPr និងសំណើច្រវាក់តម្លៃ ដែលបានជ្រើសរើស មានទិព្វភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយសំណើទាំងនោះ អាចត្រូវបានកំណត់ថាជាសំណើដែលបានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 4 | 3 | 4 | 3 | 5 | 4 | 3 | 3 | 3.6 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough; =១ |
| ៧.៥. តើ BPr និងសំណើខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយសំណើទាំងនោះ អាចត្រូវបានកំណត់ថាជាសំណើដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ? Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 2 | 3 | 3 | 1 | 2 | 3 | 3 | 1 | 2.3 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| **Total Score** | 100 | 74 | 72 | 82 | 70 | 79 | 78 | 82 | 74 | 76.4 | |

## ៦. សេចក្តីសន្និដ្ឋានរបស់គណៈកម្មការវាយតម្លៃ

យោងតាមលទ្ធផលនៃការវាយតម្លៃ និងការដាក់ពិន្ទុលើសំណើពិពិធកម្មកសិកម្មរបស់ "**សហគមន៍កសិកម្មសាមគ្គីក្រាំងសេរី**" ដែលទទួលបានពិន្ទុចំនួន **៧០.៨០** មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំសរសេរផែនការពិពិធកម្មនិងធុរកិច្ចលម្អិត។ ដូចគ្នានេះដែរ "**សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង**" ដែលទទួលបានពិន្ទុ **៧៦.៤០** មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំសរសេរផែនការពិពិធកម្មនិងធុរកិច្ចលម្អិត។ អាស្រ័យហេតុនេះ សមាជិកគណៈកម្មការ EC ទាំងអស់បានសម្រេច និងឯកភាពបញ្ជូនលទ្ធផលនៃការវាយតម្លៃនេះ ជូនទៅគណៈកម្មការ AEC ពិនិត្យ និងអនុម័តលទ្ធផលនៃការវាយតម្លៃនេះ ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍កសិកម្មទាំងពីរអាចរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្ត។

ជាកិច្ចបញ្ចប់ **លោក ឡៅ ប៉ូលីវេត** ប្រធានគណៈកម្មការ EC បានធ្វើការថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលបានចូលរួម និងស្នើសុំសមាជិកគណៈកម្មការ EC ចូលរួមកិច្ចប្រជុំបន្ទាប់ **នៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០២១** វេលាម៉ោង **០៩:០០** នាទីព្រឹក ក្នុងគោលបំណងបន្តពិនិត្យ វាយតម្លៃ និងដាក់ពិន្ទុលើសំណើពិពិធកម្មនិងសំណើធុរកិច្ចរបស់ "**សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី**" និង "**សហគមន៍កសិកម្មកសិករសាមគ្គីអមលាំង**"។ **លោកប្រធាន** បានប្រកាសបិទអង្គប្រជុំ នៅថ្ងៃដដែល វេលាម៉ោង ១២ : ០០ នាទីថ្ងៃត្រង់។

ថ្ងៃអង្គារ ៩ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២១

**រៀបចំដោយ**

**លេខាធិការ**

**ឆាន កុសល**

ថ្ងៃសុក្រ ១២ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២១

**យោបល់**

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការវាយតម្លៃ**

**ឡៅ ប៉ូលីវេត**